មជ្ឈមណ្ឌលព័ត៌មាន
ដើមអម្ពិល
DAP MEDIA CENTER

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ១២៨/១០.០៧.១៧

## គោរពជូន

### ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន

ឯកឧត្តមជាទីគោរព!

ក្នុងនាមមជ្ឈមណ្ឌលព័ត៌មានដើមអម្ពិល ដែលគ្រប់គ្រងលើប្រព័ន្ធផ្សព្វផ្សាយចំនួន 04 (សារព័ត៌មានដើមអម្ពិល, វិទ្យុដើមអម្ពិល , ទស្សនាវដ្ដីមរកត និងគេហទំព័រ WWW.Dap-News.com ) ខ្ញុំសូមសម្ដែងនូវការគាំទ្រយ៉ាងខ្លាំងក្លា ចំពោះចំណាត់ការរបស់ក្រសួងព័ត៌មាន តាមរយៈលិខិតលេខ១៨៦៣ពម ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១០ ព្រមានបិទកម្មវិធីវិទ្យុ ទូរទស្សន៍ណា ដកស្រង់អត្ថបទកាសែត ទស្សនាវដ្ដីមកអានធ្វើអត្ថាធិប្បាយ បញ្ចេញបញ្ចូល លេបខាយពាក្យសម្ដី ប្រាសចាកពីក្រមសីលធម៌ វិជ្ជាជីវៈយ៉ាងធ្ងន់ធ្ងរ ហើយការដកស្រង់នោះទៀតសោតពុំបានសុំការអនុញ្ញាតពីសាម៉ីអង្គភាពនោះឡើយ ។

ជាមួយគ្នានេះអ្វីដែលគួរឱ្យសោកស្ដាយបំផុត គឺកន្លងមកបណ្ដាអ្នកគ្រប់គ្រងស្ថានីយវិទ្យុ និង ទូរទស្សន៍ខ្លះ បែរជាមានការយល់ខុសយ៉ាងខ្លាំងថា ការដកស្រង់ព័ត៌មានពីអង្គភាពដទៃទៀតមកផ្សព្វផ្សាយ ដោយបញ្ជាក់ប្រាប់ពីប្រភព និងឈ្មោះអង្គភាពច្បាស់លាស់នោះ ជាការជួយផ្សាយឃោសនា (ឡង់សេ) ឱ្យកាសែតឬទស្សនាវដ្ដីណាមួយទៅវិញ ។ លើសពីនេះទៅទៀត វិទ្យុ ទូរទស្សន៍ខ្លះ បានលួចយកប្រភពព័ត៌មានទៅផ្សាយ ហើយថែមទាំងលេបខាយ ឱ្យម្ចាស់ប្រភពថែមទៀត ដែលទង្វើនេះក៏ប្រាសចាកពីក្រមសីលធម៌ និងសេចក្ដីថ្លៃថ្នូរផងដែរ ។

មជ្ឈមណ្ឌលព័ត៌មានដើមអម្ពិលយល់ថា ចំណាត់ការរបស់ក្រសួងព័ត៌មានខាងលើនេះ គឺជាការត្រឹមត្រូវ និងសូមចូលរួមសម្ដែងនូវការអបអរសាទរយ៉ាងខ្លាំង ។/

សូម**ឯកឧត្តមរដ្ឋមន្ត្រី**ទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១០

**អគ្គនាយក**

**សយ សុភាព**

...ះចក ខណ្ឌ ដូនពេញ ក្រុងភ្នំពេញ ទូរស័ព្ទ : ០២៣ ៧២២ ១០៦ ទូរសារ : ០២៣ ៧២២ ១០៧
...hn, Tel : 023 722 106 , Fax : 023 722 107, E-mail : dapnews@gmail.com / www.dap-news.com